# យុទ្ធនាការ «សិទ្ធិស្ត្រីក្នុងការទទួលបាន........



តមកពីទំព័រ៣

កម្មការិនី-កម្មករចូលរួមវេទិកាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយប្រជាជន

បាយ និងច្បាប់ការតាមដានការអនុវត្ត និងផ្តល់អនុសាសន៍ត្រឡប់មកវិញជាដើម។

ជាការឆ្លើយតបទៅនឹងយុទ្ធនាការនេះ សមាគមមណ្ឌលព័ត៌មានកម្មករ សហការជាមួយ សម្ព័ន្ធបងប្អូនស្រី កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៦ បានរៀបចំ វេទិកាពិគ្រោះយោបល់ស្តីពី លទ្ធផលបឋមគោលនយោបាយប្រជាជននៅមជ្ឈមណ្ឌលកម្សាន្ត លីឡា ដែលមានការចូលរួមពី កម្មការិនី- កម្មកររោងចក្រកាត់ដេរប្រមាណ ១០០នាក់។

មន្ត្រីកម្មវិធីរបស់សមាគមមណ្ឌលព័ត៌មានកម្មករ កញ្ញា សុខ ថារ៉េត បានឲ្យដឹង វេទិកាពិគ្រោះយោបល់នេះរៀបចំឡើងដើម្បីដាក់បង្ហាញនូវសេចក្តីព្រាងគោលនយោបាយដើម្បីធ្វើការបំពេញបន្ថែមនូវ ចំណុចខ្វះខាត ដោយផ្តោត លើចំណុចបីសំខាន់ៗ គឺ សិទ្ធិក្នុងការទទួលបានសេវាសុខភាពជាសាកល សិទ្ធិទទួលបានជម្រក និង សេវាចាំបាច់សម្រាប់ការរស់នៅ និងសិទ្ធិក្នុងការទទួលបានសុវត្ថិភាព និងសន្តិសុខក្នុងការរស់នៅ។ កញ្ញាបានបន្ថែមថា៖ «មុននឹងទទួលបានពង្រាងនេះ យើងបានធ្វើការពិគ្រោះសាកល្បងនៅតាមមូលដ្ឋាន ចាប់ពីខែកក្កដា ២០១៥ ដោយវិភាគទៅលើច្បាប់ដែលមានដូចជា ទឹក ភ្លើង ភូមិឃុំមានសុវត្ថិភាព និងបន្ទប់ជួល។ យើងរកឃើញចំណុចសំខាន់ៗ និងចំណុចខ្វះខាតរបស់ច្បាប់នីមួយៗ»។

ដោយឡែកនៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៦ សម្ព័ន្ធបងប្អូនស្រី បានរៀបចំវេទិកាសហគមន៍ លើកទីពីរ ដែលវេទិកានេះលើកទីមួយធ្វើឡើងនៅថ្ងៃទី ២៩ ខែមិនា ឆ្នាំ២០១៥ ក្រោមប្រធានបទ «សិទ្ធិស្ត្រីក្នុងការទទួលបានសេវាសង្គមមូលដ្ឋានប្រកបដោយគុណភាព និងសមធម៌»។ ក្នុងវេទិកានេះមានការចូលរួមពីកម្មការិនី-កម្មកររោងចក្រ ស្ត្រីប្រកបរបរផ្លូវភេទ និងអ្នកធ្វើការនៅតាមគ្រឹះស្ថានសេវាកម្សាន្ត អាជ្ញាមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល ប្រមាណជា ២២០នាក់។ នៅក្នុងវេទិកានេះក៏មានការជជែកពិភាក្សារវាងអាជ្ញាធរមូលដ្ឋាន តំណាងមណ្ឌលសុខភាព និងអ្នកចូលរួមអំពីបញ្ហាទឹក ភ្លើង ភូមិឃុំសុវត្ថិភាពជាដើម។

កម្មការិនីរោងចក្រអឹមវ៉េកាត់ដេរអន្តរជាតិ កញ្ញា ហែម សិលា ដែលបានចូលរួមជាមួយដំណើរការនេះរហូតមកបានឲ្យដឹងថា វេទិកានេះល្អសម្រាប់កម្មការិនី-កម្មកររោងចក្រអាចបញ្ចេញមតិលើចំណុចចន្លោះប្រហោងលើគោលនយោបាយដែលមានស្រាប់។ នាងបន្តថា៖ «ធម្មតាយើងជា ស្ត្រីយើងត្រូវការសុវត្ថិភាពជាចម្បង ពេលអត់មានភ្លើងបំភ្លឺផ្លូវ ខ្ញុំមានអារម្មណ៍ថាខ្លាច ហើយនៅមុខផ្ទះខ្ញុំមានក្មេងស្ទាវច្រើន។ នៅក្នុងគោលនយោបាយដែលមានស្រាប់ហ្នឹង ក៏មានចំណុចល្អដែរ បន្ទាប់ពី ចេញគោលនយោបាយ ម៉ោងប្រហែល៩យប់ ខ្ញុំធ្លាប់ឃើញប៉ូលិសជិះយាមល្បាតផ្លូវដែរ»។ សិលាបានបន្ថែមថា វេទិកាពិគ្រោះយោបល់នេះក៏ជាឱកាសល្អមួយសម្រាប់ឲ្យ កម្មការិនី-កម្មករដែលមកពី តំបន់ផ្សេងៗបានស្គាល់គ្នា និងស្វែងយល់ពីបញ្ហាគ្នាទៅវិញទៅមក។

ដោយឡែក កម្មការិនីរោងចក្រខូថប់ អ្នកស្រី ប៉ិត សម្ភស្ស បានលើកឡើងថា៖ «ខ្ញុំចង់ឲ្យគ្រូពេទ្យមានក្រមសីលធម៌ ហើយគាត់ត្រូវយកចិត្តទុកដាក់ចំពោះអ្នកជំងឺ ហើយនៅតាមមន្ទីរពេទ្យ មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ ជាពិសេសមានមន្ទីរពេទ្យនៅតាមតំបន់ដែលប្រជាជនរស់នៅ»។

ជំហានបន្ទាប់ សម្ព័ន្ធបងប្អូនស្រី តាមរយៈក្រុមគោលដៅនៅតាមមូលដ្ឋាននឹងចាប់ផ្តើមកសាង ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការបំផុសឲ្យប្រជាជននៅតាមមូលដ្ឋានយល់ដឹង ជជែក ពិភាក្សា និងអនុវត្តនូវយន្តការដែលមានស្រាប់ស្តីពីសិទ្ធិដែលពួកគាត់គួរតែទទួលបាន៕



កញ្ញា សុខ ថារ៉េតបង្ហាញពីប្រវត្តិនៃយុទ្ធនាការ

បោះពុម្ពផ្សាយដោយ
សមាគមមណ្ឌលព័ត៌មានកម្មករ WORKER'S INFORMATION CENTER
អាសយដ្ឋាន: ផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទូរស័ព្ទ: ០១៧ ២២៩ ៥០០
អ៊ីមែល: communication.wic@gmail.com
គេហទំព័រ: www.wic.unitedsisterhood.org



ព្រឹត្តិបត្រ
# ទំព័រកម្មករ
ឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ វីរភាពគួរចងចាំ






កម្មការិនី-កម្មករ រោងចក្រសាទរចំពោះវេទិការកម្មករ

# វេទិកាកម្មករ៖ «ការស្វែងយល់ពីវិស័យវាយនភណ្ឌកាត់ដេរកម្ពុជា»

សមាគមមណ្ឌលព័ត៌មានកម្មករ កាលពីថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៦ បានរៀបចំវេទិកា កម្មករ ស្តីពី «ការស្វែងយល់ពីវិស័យវាយនភណ្ឌកាត់ដេរកម្ពុជា» នៅសាលមហោស្រពចេនឡា។

វេទិកាដែលមានការចូលរួមពីកម្មការិនីកម្មកររោងចក្រកាត់ដេរ អង្គការជាតិ-អន្តរជាតិ និងអ្នកសារព័ត៌មាន ប្រមាណ ៤៥៣ នាក់នេះ ធ្វើឡើងក្នុងគោលបំណងបីសំខាន់ៗ ទីមួយគឺ ដើម្បីចូលរួមប្រារព្ធខួប លើកទី ១៣០ នៃ ទិវាពលកម្មអន្តរជាតិ ទីពីរគឺដើម្បីផ្តល់ឱកាសឲ្យកម្មករមកពីបណ្តារោងចក្រនានា បានរៀនសូត្រនិងផ្លាស់ប្តូរបទពិសោធន៍ការងារ ជាមួយគ្នា និងទីបីគឺ ដើម្បីផ្តល់ជាទីកន្លែងសម្រាប់កម្មករជួបពិភាក្សាជាមួយដៃគូពាក់ព័ន្ធនានានៅក្នុងវិស័យឧស្សាហកម្មកាត់ដេរក្នុងការស្វែងយល់ពីបញ្ហាសំខាន់ៗមួយចំនួន ដែលទាក់ទងនឹងលក្ខខណ្ឌការងារ ប្រាក់ឈ្នួល និងការធានារ៉ាប់រងសុខភាពរបស់បេឡាជាតិរបបសន្តិសុខសង្គម។

នៅក្នុងឱកាសនេះដែរ កម្មការិនី-កម្មករដែលមកពី ៦តំបន់ ជុំវិញរាជធានីភ្នំពេញ បានប្រើប្រាស់គំនិតច្នៃប្រឌិត និងទេពកោសល្យរបស់ខ្លួន ក្នុងការលើកឡើងពីបញ្ហា ក៏ដូចជាក្តីបារម្ភរបស់ខ្លួន ទាំងនៅកន្លែងធ្វើការ ក៏ដូចជាកន្លែងរស់នៅ។ កម្មការិនី ទាំងនោះបានបញ្ចេញសមត្ថភាពរបស់ខ្លួន ផ្សេងៗគ្នា ដូចជា កម្មការិនីមកពីតំបន់ចាក់អង្រែក្រោម បានជ្រើសយកការដើរបង្ហាញម៉ូដដើម្បីលើកឡើងពីបញ្ហាការកំណត់តម្លៃឡូថោកក្នុងរោងចក្ររបស់ខ្លួន។ ចំណែកកម្មការិនីមកពីតំបន់ព្រៃទា បានបង្ហាញពីបញ្ហាសុខភាព និងការកំណត់ចំនួនកើនឡើងតាមរយៈការសម្តែងរឿងខ្លី។ ដោយឡែកកម្មករ មកពីតំបន់ផ្សេងៗទៀត បានតែងជាបទចម្រៀង កំណាព្យ អាយ៉ៃ ជាដើម ដើម្បីរៀបរាប់ពីបញ្ហាដែលពួកគេបានជួបប្រទះ។

នៅដើមឆ្នាំ ២០១៦ ប្រាក់ឈ្នួលកម្មករបានកើនឡើងដល់ ១៤០ដុល្លារក្នុងមួយខែ ប៉ុន្តែកម្មករ ត្រូវប្រឈមនឹងបញ្ហាច្រើនជាងមុន។ នៅតាមរោងចក្រមួយចំនួន ការកំណត់ចំនួន(ដេរ) មានការកើនឡើងស្ទើរតែទ្វេរដង ការបង្ខំឲ្យធ្វើការថែមម៉ោងក្នុងរូបភាពផ្តល់ប្រាក់រង្វាន់ជាដើម។ ជាមួយគ្នានេះដែរនៅតាមរោងចក្រមួយចំនួនបានកាត់បន្ថយកម្មករក្នុងសង្វាក់ផលិតកម្ម។

អ្នកសម្របសម្រួលសមាគមមណ្ឌល-ព័ត៌កម្មករ លោកស្រី ម៉ាក ច័ន្ទស៊ីថា បានឲ្យដឹងថា បច្ចុប្បន្នរោងចក្រប្រមាណ ៨០ ភាគរយ ប្រើប្រាស់កិច្ច សន្យាមានថេរវេលាកំណត់ មានន័យថា នៅពេលប្រើប្រាស់កិច្ចសន្យានេះ ម្ចាស់រោងចក្រងាយស្រួលក្នុងការបញ្ឈប់ ឬបណ្តេញកម្មករចេញពីការងារដោយមិនចាំបាច់ទទួលខុសត្រូវ។ ជាមួយគ្នានេះដែរ សិទ្ធិកម្មករមិនត្រូវបានគេគោរពឡើយ។

លោកស្រី ម៉ាក ច័ន្ទស៊ីថា បានលើកឡើងថា រោងចក្រនៅកម្ពុជាមានចំនួនជាង ៦៥៥រោងចក្រ ក្នុងនោះប្រមាណ១៥%

តទៅទំព័រ២

# វេទិកាកម្មករ៖ «ការស្វែងយល់ពីវិស័យ...













កម្មការិនី-កម្មករសម្តែងសិល្បៈដើម្បីបង្ហាញពីស្ថានភាពរស់នៅ និងស្ថានភាពការងាររបស់ខ្លួន

តមកពីទំព័រ១

ជារោងចក្រផលិតស្បែកជើង ដែលប្រើប្រាស់កម្លាំងពលកម្មកម្មករប្រហែល ៦២មុឺននាក់ ហើយ ៨៦ភាគរយជាស្ត្រី។ លោកស្រីបន្តថា វិស័យវាយនភណ្ឌកាត់ដេរ គឺជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិកម្ពុជា។ ជាក់ស្តែង កាលពីឆ្នាំ២០១៥ ចំណូលទទួលបានពីការនាំចេញមានចំនួន ៦ ២៧៩លានដុល្លារ។

ដើម្បីបើកឱកាសឲ្យកម្មការិនី-កម្មករទទួលបានបទពិសោធ និងចំណេះដឹងថ្មីៗ សមាគមមណ្ឌលព័ត៌មានកម្មករ បានអញ្ជើញវាគ្មិនកិត្តិយសមកចែករំលែកពីបទពិសោធន៍ទាក់ទងនឹងការងាររបស់ពួកគាត់។ លោកស្រី ឱក ម៉ូលីកា តំណាងអង្គការអន្តរជាតិខាងការងារ លោក អាត់ ធន់ ប្រធានសហព័ន្ធសហជីពស៊ីខៅឌូ និងលោកស្រី ឆន សុខា មន្ត្រីមជ្ឈមណ្ឌលសម្ព័ន្ធការងារ និងសិទ្ធិមនុស្សបានចែករំលែកពីបញ្ហា សុខភាព និងបេឡាជាតិរបបសន្តិសុខសង្គម និងលោក អន ណន តំណាងសមាគមសិទ្ធិកម្មករ (WRC) និងលោក ម៉ៃ សុភ័ក្រ្តា អគ្គលេខាធិការសហជីពកាទូ ចែករំលែកពីបញ្ហាលក្ខខណ្ឌការងារ និងប្រាក់ឈ្នួល។

កម្មការិនី ទឹង ម៉េងលី រោងចក្រហ្គ្រេនធ្វីន បាននិយាយថា «ខ្ញុំមានអារម្មណ៍រំភើប នូវអ្វីដែល WIC (មណ្ឌលព័ត៌មានកម្មករ) បានរៀបចំ ជាពិសេស គឺវគ្គសំណួរចម្លើយពី បសស ជាលើកទីមួយសម្រាប់ខ្ញុំ ធ្វើឲ្យខ្ញុំចងចាំមិនភ្លេច ហើយអ្វីដែលនៅតែមិនទាន់អស់ចិត្តនោះ គឺខ្ញុំមិនបានលើកពីបញ្ហាស្ត្រីមានផ្ទៃពោះត្រូវគេដេរ ពេលទៅបន្ទប់ទឹកញឹកញាប់ ព្រោះពេលទៅវេទិកាប្រធានក្រុមចូលរួមក្នុងវេទិកាដែរ ខ្លាចមកវិញមើលមុខគ្នាអត់ចំតែអ្វី ដែលគួរឲ្យចាប់អារម្មណ៍ គឺពេលមកវិញគាត់កាត់បន្ថយការដេរកូនក្រុម ហាក់ដូចជាបន្ទន់ឥរិយាបថ»។

ស្រដៀងគ្នានេះដែរ កម្មករ យ៉ែម ស៊ុណាត រោងចក្ររ៉ូស៊ីង (ហៅអាយឡែន)បានឲ្យដឹងថា «វេទិកានេះល្អណាស់សម្រាប់កម្មករ ព្រោះកម្មករបានដឹងពីព័ត៌មានថ្មីទាក់ទងនឹងសេវាធានារ៉ាប់រងសុខភាព ហើយធ្វើឲ្យកម្មករមានឱកាសសួរទៅកាន់អ្នកពាក់ព័ន្ធ ហើយអ្វីដែលសំខាន់គឺខ្ញុំបានស្គាល់សម្ព័ន្ធបងប្អូនស្រីដែលតែងតែរៀបចំឲ្យមាន វេទិកាជួបជុំហើយខ្ញុំចង់បន្តឲ្យមានបែបនេះទៀត»។

កម្មការិនី-កម្មករភាគច្រើនបានសាទរចំពោះការរៀបចំវេទិកាកម្មករនេះ៕

## ភាសាអង់គ្លេសបានបង្កើនសមត្ថភាពកម្មការិនីរោងចក្រឲ្យទទួលតំណែងប្រសើរជាងមុន

ភាសាអង់គ្លេស ជាភាសាមួយដ៏ពេញនិយមសម្រាប់ការប្រាស្រ័យទាក់ទងគ្នា រវាងជនជាតិបរទេស និងប្រជាពលរដ្ឋកម្ពុជា។ ជនបរទេសទាំងនោះភាគច្រើនជា វិនិយោគិន ទេសចរ ដែលធ្វើដំណើរមកប្រទេសកម្ពុជា។

ភាសានេះក៏ជាយានមួយផងដែរ ក្នុងការចម្លងជីវិតមនុស្សមួយចំនួនឲ្យរួចផុតពីការលំបាកនានា។ កម្មការិនី រឿន ចំរើន ទោះបីជាមមាញឹកនឹងការងាររោងចក្រយ៉ាងណាក៏ដោយ នាងនៅតែឆ្លៀតពេល សម្រាប់រៀនភាសាអង់គ្លេស។ នាងរំពឹងទុកថា ថ្ងៃណាមួយជីវិតរបស់នាងនឹងប្រសើរឡើង។ នាងនឹងអាចរួចផុតពីជីវិតកម្មករដែលប្រើប្រាស់កម្លាំងពលកម្ម។ ក្រោយពីការព្យាយាម នៅទីបំផុតក្តីស្រមៃរបស់នាងបានក្លាយជាការពិត។

កម្មការិនី រឿន ចំរើន មានស្រុកកំណើតនៅខេត្តបាត់ដំបង។ នាងជាកូនទីពីរក្នុងចំណោមបងប្អូនបួននាក់។ ការរស់នៅជាមួយម្តាយជាស្ត្រីមេម៉ាយ បានធ្វើឲ្យចំរើនសម្រេចចិត្តឈប់រៀនថ្នាក់ទី៩។ នាងបានមកធ្វើការរោងចក្រស្បែកជើងនៅភ្នំពេញ ខណៈពេលនាងមានអាយុត្រឹមតែ ១៦ឆ្នាំ។

ហេតុតែការស្រលាញ់ការសិក្សា ចំរើន បានឆ្លៀតពេលពីការមមាញឹកនឹងការងារដើម្បីរៀនភាសាអង់គ្លេស។ ឆ្នាំ ២០១២ កម្មការិនីវ័យ ២៧ឆ្នាំនេះ បានចូលរៀនភាសាអង់គ្លេសនៅមណ្ឌលសំចតពោធិ៍សែនជ័យរបស់សមាគមមណ្ឌលព័ត៌មានកម្មករ។

ក្នុងវគ្គរៀនភាសាអង់គ្លេសនេះ គឺរៀនមួយសប្តាហ៍ ៣ថ្ងៃ និងមួយថ្ងៃមួយម៉ោង។ ដោយសារចង់បន្ថែមចំណេះដឹងភាសាអង់គ្លេសឲ្យកាន់តែប្រសើរឡើង នៅដើមឆ្នាំ ២០១៦ ចំរើន បានចុះឈ្មោះចូលរៀននៅសាលាឯកជនមួយកន្លែង ដោយរៀនមួយ ថ្ងៃបីម៉ោង រៀនពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។

សមាគមមណ្ឌលព័ត៌មានកម្មករ តាមរយៈមណ្ឌលសំចតទាំងប្រាំមួយរបស់ខ្លួន បានផ្តល់ជាកន្លែងសិក្សាភាសាខ្មែរ និងភាសាអង់គ្លេសដល់កម្មការិនី-កម្មកររោងចក្រ ពីរថ្ងៃក្នុងមួយសប្តាហ៍។ ថ្នាក់ទាំងពីរនេះមាន សិស្សសរុប ៧១នាក់។

មូលហេតុដែល ចំរើន ជ្រើសរើសរៀនភាសាអង់គ្លេសព្រោះនាងចង់ផ្លាស់ប្តូរជីវិតរបស់ខ្លួន ឲ្យប្រសើរឡើង។ ម្យ៉ាងទៀត នាងចង់ប្រើប្រាស់ភាសានេះដើម្បីទំនាក់ទំនងជាមួយជនបរទេស។ នាងបន្តថា «ខ្ញុំចង់ចេះនិយាយជាមួយ Buyers (អ្នកបញ្ជាទិញ) ពេលគាត់មករោងចក្រ ដើម្បីឲ្យគាត់ ដឹងពី ស្ថានភាពរោងចក្រដែលមានការបង្ខំ ការគាបសង្កត់ ប៉ុន្តែមិនមែនយើងនិយាយបង្ខូចរោងចក្រទេ តែយើង និយាយពីស្ថានភាពជាក់ស្តែង»។

ការរៀនភាសាអង់គ្លេសនេះ បានជំរុញឲ្យកម្មការិនីរោងចក្ររូបនេះផ្លាស់ប្តូរតំណែងថ្មីដែលល្អប្រសើរ ជាងមុន។ ដើមឆ្នាំ២០១៦ រោងចក្រហ្វងក្លូរី (ខេមបូឌា) បានជ្រើសរើសបុគ្គលិកក្នុងតំណែងពិនិត្យ (QC)។ ក្រោយទទួលបានព័ត៌មាននេះពីមិត្តភក្តិ ចំរើន បានសម្រេចចិត្តដាក់ពាក្យ។ បន្ទាប់មកខាងរោងចក្រឲ្យនាងសាកល្បងការងារ និងសម្ភាសភាសាអង់គ្លេសនាង។ ជាលទ្ធផល នាងត្រូវរោងចក្រទទួលឲ្យធ្វើការ។

ការងារចម្បងរបស់ ចំរើន ដែលត្រូវប្រើប្រាស់ភាសាអង់គ្លេសគឺការសរសេររបាយការណ៍ ការប្រជុំជាមួយប្រធានផ្នែក និងការប្រើប្រាស់ពាក្យបច្ចេកទេសជាដើម។

ភាសាអង់គ្លេសជាភាសាបរទេសសម្រាប់ប្រជាពលរដ្ឋខ្មែរ ដូច្នេះវាមិនមែនជារឿងងាយស្រួលនោះទេក្នុងការរៀនសូត្រភាសានេះ។ មុននឹងទទួលបានជោគជ័យដូច បច្ចុប្បន្ន ពេលខ្លះនាងស្ទើរតែបោះបង់ការរៀននេះ។ នាងនិយាយថា ពេលចូលរៀនដំបូង នាងមាន អារម្មណ៍ខ្មាសគេព្រោះតែរៀនអត់ចេះ។ ប៉ុន្តែដោយសារការលើកទឹកចិត្តពីគ្រូបង្រៀន ទើបនាងកម្លាំងចិត្តរៀនបន្ត។ ការធ្វើការបណ្តើរ រៀនបណ្តើរគឺជារឿងលំបាកមួយសម្រាប់បុគ្គលគ្រប់រូប សម្រាប់ ចំរើន ក៏មិនខុសគ្នាដែរ។ ប៉ុន្តែនាងមានវិធីសាស្ត្រក្នុងការរៀន។ នាងបានឲ្យដឹងថា៖ «ខ្ញុំខំប្រឹងមើលសៀវភៅ ខ្ញុំថតសំឡេងដាក់ទូរសព្ទ ឧទាហរណ៍ពាក្យ book (សៀវភៅ) ចឹងគេ spell (ប្រកប) យ៉ាងម៉េច ហើយបកថាម៉េច ខ្ញុំអានហើយថតទុក ខ្ញុំស្តាប់នៅពេលចូលគេង ខ្ញុំព្យាយាមមើលសៀវភៅ ព្យាយាមសរសេររហូតខ្ញុំបានចំណាត់ថ្នាក់លេខ២នៅក្នុងថ្នាក់ ហើយទទួលរង្វាន់លើកទឹកចិត្តពីគ្រូ»។



កញ្ញា រឿន ចំរើន

ជាចុងក្រោយ ចំរើន សំណូមពរឲ្យកម្មករទាំងអស់គួរតែផ្តោតលើការសិក្សា។ ទោះបីជា ភាសាអង់គ្លេសជាភាសាបរទេស តែវាជួយផ្តល់ឱកាសឲ្យកម្មករអាចផ្លាស់ប្តូរខ្លួនឯង។ ម្យ៉ាងវិញទៀត នាងថា ការសិក្សាភាសានេះពិតជាមានការលំបាក ប៉ុន្តែដរាបណាមិនទាន់ខំអស់ពីសមត្ថភាព សូមកុំបោះបង់ និងកុំគិតថាខ្លួនឯងធ្វើមិនបាន៕

## យុទ្ធនាការ «សិទ្ធិស្ត្រីក្នុងការទទួលបានសេវាសង្គមមូលដ្ឋានប្រកបដោយគុណភាពនិងសមធម៌»

សម្ព័ន្ធបងប្អូនស្រីចាប់តាំងពីឆ្នាំ ២០១៥ បានផ្តួចផ្តើមរៀបចំយុទ្ធនាការមួយស្តីពីសិទ្ធិស្ត្រីក្នុងការទទួលបានសេវាសង្គមមូលដ្ឋានប្រកបដោយគុណភាព និងសមធម៌។ យុទ្ធការនេះនៅតែបន្តរហូតមកដល់សព្វថ្ងៃនេះ។

យុទ្ធនាការនេះបង្កើតបានជា គោលនយោបាយប្រជាជនដែលជាឯកសារគោលគំនិតក្នុងការបង្ហាញពីការអនុវត្តជាក់ស្តែង តម្រូវការ ការទាមទារ និងដំណោះស្រាយជាអនុសាសន៍របស់ប្រជាជន ជាពិសេសស្ត្រីជាកម្មការិនីរោងចក្រ និងស្ត្រីប្រកបសេវាកម្សាន្ត។

យុទ្ធនាការនេះមានគោលបំណងសំខាន់ៗចំនួន៣ គឺទីមួយ ជំរុញឲ្យរដ្ឋាភិបាល និងស្ថាប័ន ដែលពាក់ព័ន្ធយកចិត្តទុកដាក់លើបញ្ហាស្ត្រី និងស្វែងរកដំណោះស្រាយរួមគ្នាជាមួយនឹងស្ត្រី ដែល យុទ្ធនាការនេះដឹកនាំដោយស្ត្រីមកពីពីរវិស័យគឺវិស័យវាយនភណ្ឌកាត់ដេរកម្ពុជា និង វិស័យសេវាកម្សាន្ត ទីពីរ ចាប់ផ្តើមស្វែងយល់ និងផ្តោតទៅលើសិទ្ធិក្នុងការទទួលបានសេវាសង្គមមូលដ្ឋានដោយពិនិត្យមើលច្បាប់ គោលនយោបាយជាតិ និងយន្តការដែលមានស្រាប់ និងទីបីដើម្បីឲ្យមានការបញ្ចូលស្ត្រី ឬឲ្យស្ត្រីចូលរួមក្នុងដំណើរការអភិវឌ្ឍន៍គោលនយោ-

តទៅទំព័រ៤